

# ការប្តេជ្ញាចិត្តចំពោះ និរន្តភាពរបស់យើង

# ទិដ្ឋភាពទូទៅនៃសមិទ្ធិផលសង្គម និងបរិស្ថាន

ចាប់តាំងពីពេលដែលបានបង្កើតក្រុមការងារនៅក្នុងឆ្នាំ ២០១៩ មក ហ្វីស ហ្វាយនែន នៅតែបន្តការផ្តល់ប្រឹក្សាអំពីព័ត៌មានទូទៅបន្ថែមទាក់ទងទៅនឹងកម្ចីលំនៅដ្ឋានទៅកាន់សាធារណជន និងអតិថិជនរបស់ខ្លួន ដែលវាគឺជាផ្នែកនៃបេសកកម្មសង្គមក្នុងការផ្តល់សេវាមិនមែនហិរញ្ញវត្ថុ ។ សាធារណជនអាចទូរសព្ទសាកសួរអំពីដំណើរការក្នុងការកាត់ប្លង់ របៀបពិនិត្យមើលពីភាពស្របច្បាប់របស់អ្នកអភិវឌ្ឍអចលនទ្រព្យ និងបញ្ហាផ្សេងទៀតទាក់ទងទៅនឹងផ្ទះសម្បែង ។ ជាមួយគ្នានេះផងដែរ យើងខ្ញុំបានបង្កើតអត្ថបទអប់រំខ្លីៗ រួចដាក់បង្ហាញនៅលើបណ្តាញសង្គមហ្វេសប៊ុក ។ ក្នុងឆ្នាំ ២០២២ អត្ថបទខ្លីៗទាំងនោះមានប្រមាណជិត ៦០អត្ថបទ ត្រូវបានចែកចាយនៅលើបណ្តាញសង្គម ដែលអត្ថបទនីមួយៗបានទៅដល់អ្នកអានប្រមាណ ៥០០ នាក់ ។ ហ្វីស ហ្វាយនែន ពិតជាមានមោទកភាពដលែបានចូលរួមបង្កើននូវចំណេះដឹងបន្ថែមទៅកាន់សាធារណជន ដើម្បីឱ្យពួកគាត់អាចការពារខ្លួនឯងបាន និងធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវ ក្នុងការជ្រើសរើសទិញអចលនទ្រព្យដែលជាលំនៅដ្ឋានរបស់ពួកគាត់ ។

ហ្វីស ហ្វាយនែន បានឈានមួយជំហានទៀត ក្នុងការគ្រប់គ្រងសមិទ្ធិផលសង្គម និងបរិស្ថានប្រកបដោយប្រសិទ្ធិភាព តាមរយៈការបង្កើតគោលនយោបាយគ្រប់គ្រងសមិទ្ធិផលសង្គម និងបរិស្ថាន ការបង្កើតក្របខណ្ឌហិរញ្ញវត្ថុសង្គម និងរបាយការណ៍ដែលវាត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយស្ថាប័នមួយឈ្មោះថា Moody's ។ យើងខ្ញុំក៏បានផ្តល់ការអប់រំអំពីការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន ព្រមជាមួយរបៀបនៃការកាត់បន្ថយ និងគ្រប់គ្រងហានិភ័យទាំងនោះទៅកាន់បុគ្គលិក អតិថិជន និងសហគមន៍ ។ ហ្វីស ហ្វាយនែន បានដាក់បញ្ចូលការវាយតម្លៃពីផលប៉ះពាល់សង្គម និងបរិស្ថានចូលទៅក្នុងនិតិវិធីសិក្សាវាយតម្លៃឥណទាន ក៏ដូចជាដំណើរការពិនិត្យ និងតាមដានឥណទានក្នុងគោលបំណងការពារ និងកាត់បន្ថយគ្រោះថ្នាក់ដល់បរិស្ថាន និងចូលរួមលើកតម្កើងឱ្យមានសមភាព និងសមធម៌ក្នុងសង្គម ។ យើងខ្ញុំនឹងធ្វើការត្រួតពិនិត្យ និងវាយតម្លៃឥណទានឡើងវិញជាប្រចាំឆ្នាំសម្រាប់កម្ចីដែលធំជាង ៣ម៉ឺនដុល្លារឡើង ។

## គោលការណ៍បរិស្ថាន និងសង្គម



តែងតែគិតគូរពីផលប៉ះពាល់សង្គម និងបរិស្ថាននៅគ្រប់សេចក្តីសម្រេចចិត្ត ដោយរួមបញ្ចូលការគ្រប់គ្រងធនធានមនុស្ស និងផលប៉ះពាល់ពីប្រតិបត្តិការ ហិរញ្ញប្បទាន និងលទ្ធកម្ម



អនុលោមតាមច្បាប់ទាំងឡាយទាក់ទងទៅនឹងបរិស្ថាន រួមមានបទបញ្ញត្តិរបស់ប្រទេសកម្ពុជា ច្បាប់អន្តរជាតិ និងការអនុវត្តន៍ផ្សេងៗ ដើម្បីធានានិរន្តរភាពប្រតិបត្តិការ កំណើនអតិថិជន និងកាត់បន្ថយហានិភ័យ



ធ្វើប្រតិបត្តិការដោយប្រុងប្រយ័ត្ន ដោយមានការយកចិត្តទុកដាក់ត្រឹមត្រូវ និងមានការត្រួតពិនិត្យយ៉ាងទៀងទាត់ ក្នុងការវាយតម្លៃ និងចាប់យកគោលការណ៍នោះមកអនុវត្តន៍ ដើម្បីការពារ និងកាត់បន្ថយគ្រោះថ្នាក់ទៅដល់បរិស្ថាន ក៏ដូចជាលើកតម្លើងសមភាព និងសមធម៌សង្គម



ចូលរួមជាមួយភាគីពាក់ពន្ធ័ ក្នុងការគ្រប់គ្រងហានិភ័យសង្គម និងបរិស្ថាន និងកំណត់ឱ្យបាននូវឱកាសដើម្បីធ្វើឱ្យមានភាពប្រសើរឡើង

គោលការណ៍របស់យើងខ្ញុំត្រូវបានបង្កើតឡើង ស្រប ទៅតាមការប្ដេជ្ញាចិត្តរបស់យើងខ្ញុំ ក៏ដូចជាស្របទៅ នឹង គោលដៅអភិវឌ្ឍប្រកបដោយស្ថេរភាពរបស់ អង្គការសហប្រជាជាតិ (UN SDGs)។ យើងខ្ញុំបាន ផ្ដួងគោលការណ៍របស់យើងទៅនឹង ១០ គោលដៅ អភិវឌ្ឍប្រកបដោយស្ថេរភាពរបស់អង្គការសហប្រជាជាតិ អាស្រ័យតាមកិច្ចការដែលមានផលប៉ះពាល់ច្រើនជាងគេ




## សមិទ្ធផលបរិស្ថាន និងសង្គម

### សកម្មភាព និងអាជីវកម្មដែលមានស្ថេរភាព

| ស្របតាមគោលការណ៍ UN SDGs | ការវាស់វែង | សមិទ្ធផលឆ្នាំ ២០២២ |
|---|---|---|
|  | **ចំណេះដឹង និងបរិយាបន្នហិរញ្ញវត្ថុ**<br>ការផ្ដល់សេវាហិរញ្ញវត្ថុ ទៅកាន់គ្រួសារដែលមានចំណូលទាបនិងមធ្យម និង គ្រួសារដែលមានផ្ទះជាលើកដំបូង | • ៦២% នៃអតិថិជនមានចំណូលក្រោម ៧០០ ដុល្លារ ក្នុង ១ខែ<br>• ផ្ដល់សេវាហិរញ្ញវត្ថុទៅដល់ ២.១៧៩ គ្រួសារ ជាមួយផលបត្រឥណទាន ៣៥,៨ លានដុល្លារ<br>• ៦៤% នៃអតិថិជន គឺជាស្ត្រី<br>• ៦៣% នៃអតិថិជន គឺជាអ្នកដែលមានផ្ទះដំបូងក្នុងជីវិត<br>• អត្ថបទខ្លីៗ ចំនួន ៥៩ ស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន និងចំណេះដឹងអំពីសិទ្ធិអចលនទ្រព្យត្រូវបានបង្កើតនិងផ្សព្វផ្សាយលើបណ្ដាញសង្គម |
| | លទ្ធភាពទទួលបានសេវាកម្ចីលំនៅដ្ឋានខ្នាតតូច ទឹកស្អាត និងអនាម័យ | • ប្រហែល ៦០% នៃអតិថិជន បានប្រើប្រាស់សេវាកម្ចី លំនៅដ្ឋានខ្នាតតូចដើម្បីកែប្រែគុណភាពជីវិតឱ្យបានប្រសើរឡើង |
| | **បទពិសោធន៍អតិថិជន**<br>ការឱ្យពិន្ទុទៅលើភាពពេញចិត្ត<br><br>កម្រិតនៃការថែរក្សាអតិថិជន | • ៧៥% នៃអតិថិជន ពេញចិត្តពីសេវាអតិថិជន<br><br>• កម្រិតថែរក្សាអតិថិជន ៧៧,៣% |
| | **ភាពចម្រុះ និងបរិយាបន្ន**<br>តួនាទីស្ត្រីនៅក្នុងជួរថ្នាក់ដឹកនាំ | • ១០% |
| | **បម្រែបម្រួលអាកាសធាតុ**<br>ការបំភាយឧស្ម័នផ្ទះកញ្ចក់ | • បរិមាណប្រេងឥន្ធនៈ(លីត្រ)៖ ៤៤.៩៥៦<br>• បរិមាណភ្លើងអគ្គិសនី៖ ១៨៧.៤៩៩ |

## ទំនួលខុសត្រូវផ្នែកសង្គម

| ស្របតាមគោលការណ៍ UN SDGs | ការវាស់វែង | សមិទ្ធិផលឆ្នាំ ២០២២ |
|---|---|---|
| <br> | **ការតបស្នងទៅកាន់សហគមន៍**<br>ការអភិវឌ្ឍន៍ធនធានមនុស្ស | • អនុវត្តន៍គម្រោងបណ្ណាល័យចំនួន ៣ |

## អភិបាលកិច្ច និងហានិភ័យ

| ស្របតាមគោលការណ៍ UN SDGs | ការវាស់វែង | សមិទ្ធិផលឆ្នាំ ២០២២ |
|---|---|---|
| <br> | **អភិបាលកិច្ច និងក្រមសីលធម៌**<br>មានគោលនយោបាយត្រឹមត្រូវក្នុងការគាំទ្រទៅដល់សកម្មភាព និងអាជីវកម្មប្រកបដោយស្ថេរភាព<br><br>ត្រួតពិនិត្យ និងតាមដានកម្ចីដើម្បីធានាបានថាប្រភពចំណូលអតិថិជនមិនប៉ះពាល់ទៅដល់បរិស្ថាន និងសង្គម | • កែសម្រួលនីតិវិធីគ្រប់គ្រងសមិទ្ធិផលសង្គម និងបរិស្ថាន<br>• បង្កើតគោលការណ៍ សុវត្ថិភាព និងសន្តិសុខ<br>• កែសម្រួលយន្តការណ៍ដោះស្រាយបណ្តឹង<br>• ដាក់បញ្ចូលបញ្ជីអាជីវកម្មដែលហាមឃាត់ចូលទៅក្នុងនីតិវិធីវាយតម្លៃ និងត្រួតពិនិត្យឥណទាន<br>• កែសម្រួលនីតិវិធីរាយការណ៍ជាសម្ងាត់<br>• កែសម្រួលក្រមសីលធម៌<br>• កែសម្រួលនីតិវិធី និងគោលនយោបាយឥណទាន<br>• បង្កើតនីតិវិធីគ្រប់គ្រងហានិភ័យឥណទាន<br>• កែសម្រួលនីតិវិធីប្រតិបត្តិតាម<br>• កែសម្រួលគោលនយោបាយធនធានមនុស្ស |
| | ស្ត្រីនៅក្នុងជួរក្រុមប្រឹក្សាភិបាល | • 0 |

## ចូលរួមជាមួយអ្នកពាក់ពន្ធ័ និងតស៊ូមតិ

| ស្របតាមគោលការណ៍ UN SDGs | ការវាស់វែង | សមិទ្ធិផលឆ្នាំ ២០២២ |
|---|---|---|
| <br> | **ការទាក់ទាញ អភិវឌ្ឍ និងថែរក្សាបុគ្គលិក**<br>ចំនួនបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលលើការគ្រប់គ្រងសមិទ្ធិផលសង្គម និងបរិស្ថាន | • ដោយគោលនយោបាយទើបតែបានបង្កើត ដូច្នេះការផ្តល់ជូនវគ្គបណ្តុះបណ្តាលនៅត្រូវធ្វើឡើងនៅដើមឆ្នាំ ២០២៣ ដោយដាក់បញ្ចូលទៅក្នុងកម្មវិធីតម្រង់ទិសសម្រាប់បុគ្គលិកថ្មី និងវគ្គរំលឹកឡើងវិញ ។ |

# ការទទួលស្គាល់កម្រិតខ្ពស់ក្នុងការអនុវត្តន៍គោលការណ៍ការពារអតិថិជន




ជាមួយបេសកកម្មសង្គមក្នុងការពង្រីកវិសាលភាព ផ្តល់សេវាកម្ចីលំនៅដ្ឋានខ្នាតតូចរយៈពេលវែងទៅដល់គ្រួសារដែលមានចំណូលទាប និងមធ្យម ដើម្បីផ្តល់លទ្ធភាពឱ្យពួកគាត់មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន និងបានរស់នៅក្នុងជីវភាពមួយដែលមានស្ថេរភាព ហ្វឹស ហ្វាយនែន បានប្តេជ្ញាក្នុងការការពារមិនឱ្យមានបំណុលវណ្ណករ ការយកចិត្តខ្ពស់ ក៏ដូចជាការផ្តល់ជូននូវតម្លាភាពសម្រាប់គ្រប់អតិថិជនទាំងអស់ ។ ការទទួលបានវិញ្ញាបនបត្រកម្រិតខ្ពស់បំផុតពីស្ថាប័ន M-Cril នៅក្នុងឆ្នាំ ២០២២ បានបញ្ជាក់យ៉ាងច្បាស់អំពីការប្តេជ្ញាចិត្តរបស់យើងខ្ញុំ ក្នុងការអនុវត្តន៍នូវគោលការណ៍ការពារអតថិជននៅក្នុងគ្រប់សកម្មភាពប្រតិបត្តិការប្រចាំថ្ងៃរបស់យើងខ្ញុំ ។ គោលការណ៍ទាំងនោះរួមមាន (១) ការបង្កើត និងផ្តល់ផលិតផលដែលសមរម្យ (២) ការការពារការជាប់បំណុលវណ្ណករ (៣) តម្លាភាព (៤) ការកំនត់តម្លៃដែលមានការទទួលខុសត្រូវ (៥) ការដោះស្រាយជាមួយអតិថិជនដោយគោរព និងយុត្តិធម៌ (៦) ការរក្សាព័ត៌មានសម្ងាត់របស់អតិថិជន (៧) យន្តការសម្រាប់ដោះស្រាយបណ្តឹង ឬការតវ៉ារបស់អតិថិជន ។